**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

**ផ្ញើជូន**
**លោកជំទាវ ខួន ធួន**

***លោកជំទាវជាទីរាប់អាន,***

យើងខ្ញុំជាថ្នាក់ដឹកនាំ និងមន្រ្តីរាជការនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ទាំងអស់បានទទួលដំណឹងដ៏ក្រៀមក្រំថា ឯកឧត្តម **មិន ឃិន** ទេសរដ្ឋមន្រ្តីទទួលបន្ទុកបេសកកម្មពិសេស ត្រូវជាស្វាមីលោកជំទាវ បានទទួលមរណភាពនាថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១៦ ក្នុងជន្មាយុ៧៨ឆ្នាំ ដោយរោគាពាធ។

យើងខ្ញុំទាំងអស់គ្នាមានការសោកស្តាយចំពោះការបាត់បង់ សមាជិករាជរដ្ឋាភិបាលដ៏ឧត្តុងឧត្តមម្នាក់ដែលជាស្វាមីជាទីស្រឡាញ់របស់លោកជំទាវ ជាបិតា និងជីតាប្រកបដោយព្រហ្មវិហារធម៌ មានទឹកចិត្តប្រពៃថ្លៃថ្លា ជាកុលបុត្រដ៏ឆ្នើមមួយរូបដែលបានចូលរួមបម្រើសង្គម និងបានរួមចំណែកយ៉ាងសកម្មក្នុងការកសាងជាតិទាំងខាងផ្នែកសង្គម ទាំងផ្នែកសាសនា ក្នុងអាយុកាលរស់នៅរបស់ឯកឧត្តម។

ក្នុងឱកាសដ៏សែនក្រៀមក្រំបំផុតនេះ យើងខ្ញុំទាំងអស់គ្នាដែលជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សូមសម្តែងនូវការស្តាយស្រណោះក្រៃលែង និងសូមចូលរួមរំលែកនូវមរណទុក្ខជាមួយលោកជំទាវ និងក្រុមគ្រួសារប្រកបដោយសមានទុក្ខ និងក្តីសង្វេគជាទីបំផុត។

ជាថ្មីម្តងទៀត យើងខ្ញុំទាំងអស់គ្នាដែលជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សូមឧទ្ទិសបួងសួងដល់ដួងវិញ្ញាណក្ខន្ធឯកឧត្តម **មិន ឃិន** សូមអញ្ជើញទៅកាន់សុគតិភព កុំបីឃ្លៀងឃ្លាតឡើយ។

សូមលោកជំទាវទទួលនូវការគោរពរាប់អានដ៏ស្មោះអំពីយើងខ្ញុំ៕

រាជធានីភ្នំពេញ ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១៦
**ទេសរដ្ឋមន្ត្រី**
**និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

**អៀង មូលី**

អាសយដ្ឋាន ៖ អគារលេខ១៦ ផ្លូវលេខ២៧១កែង១៥០ សង្កាត់ទឹកល្អក់II ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទ: (855) 23 885 129 • ទូរសារ : (855) 23 885 279 • E-mail: info@naaa.gov.kh • Website: naaa.gov.kh